បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២.៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ឆ្នាំទី ៧ លេខ ១២ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៨-៣-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៧៥ តែងតាំង និងតម្លើងឋានន្តរស័ក្តិ និងផ្លាស់ប្តូរមុខងារនាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទ ៦០២


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


២៥-៣-១៩៩៩ -អនុក្រឹត្យលេខ ៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៣

២៩-៣-១៩៩៩ -អនុក្រឹត្យលេខ ៨៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦០៤

៣០-៣-១៩៩៩ -អនុក្រឹត្យលេខ ៨៩ អនក្រ.តត ស្តីពីការ តម្លើងឋានន្តរស័ក្តិ ៦០៥


### ២-សារាចរណែនាំ


២៩-៣-១៩៩៩ -សារាចរណែនាំលេខ ០៣ សរណន ស្តីពីការរៀបចំ បុណ្យចូលឆ្នាំថ្មី ឆ្នាំថោះ ឯកស័ក ពស ២៥៤៣ គស ១៩៩៩ ៦០៦

២៩-៣-១៩៩៩ -សារាចរណែនាំ លេខ ០៤ សរណន ស្តីពីការរៀបចំ បុណ្យវិសាខបូជា និង ព្រះរាជពិធីច្រត់ព្រះនង្គ័ល ៦០៨


## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការគណៈរដ្ឋមន្ត្រី

#### ប្រកាស


២៩-៣-១៩៩៩ -ប្រកាសលេខ ៤២ ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៦១១

៣១-៣-១៩៩៩ -ប្រកាសលេខ ៤៣ ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៦១២


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ


២៥-៣-១៩៩៩ -ប្រកាសលេខ ១១១ ប្រក.សហវ រតន ស្តីពីការបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យរបស់រដ្ឋ ៦១៣


### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

#### ប្រកាស

២៥-៣-១៩៩៩ -ប្រកាសលេខ ៣៥៩ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ជាស៊ីណាត ហ្គាមេន ខូ អិលធីឌី តំណាងដោយលោកស្រី ជា ស៊ីណាត ជនជាតិខ្មែរ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ៦១៥

## ៤-នីស្ដីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

៣០-៣-១៩៩៩ -ប្រកាសលេខ ០៧៧ បទ.ប្រក ស្ដីពីការតម្លើងតួនាទី និងតែងតាំងមន្ត្រីរាជការ ៦១៦

៣០-៣-១៩៩៩ -ប្រកាសលេខ ០៧៨ បទ.ប្រក ស្ដីពីការតម្លើងតួនាទី និង តែងតាំងមន្ត្រីរាជការ ៦១៧

៣០-៣-១៩៩៩ -ប្រកាសលេខ ០៧៩ បទ.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ ៦១៩

៣០-៣-១៩៩៩ -ប្រកាសលេខ ០៨០ បទ.ប្រក ស្ដីពីការតម្លើងតួនាទី និង តែងតាំងមន្ត្រីរាជការ ៦២០

៣០-៣-១៩៩៩ -ប្រកាសលេខ ០៨១ បទ.ប្រក ស្ដីពីការបង្កើតមណ្ឌលវិទ្យុចល័ត ៦២១

## ៥-នីស្ដីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

### ប្រកាស

២៦-៣-១៩៩៩ -ប្រកាសលេខ ១២៥ សក.បយ ស្ដីពីការអនុញ្ញាតអោយក្រុមហ៊ុន ខេម ម៉ាស់ ខូអិលធីឌី ធ្វើការរៀបចំ និង ដំណើរការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ៦២២

## ៦-នីស្ដីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

### ប្រកាស

៣០-៣-១៩៩៩ -ប្រកាសលេខ ១២ ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ ៦២៤

## ៧-រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

### សេចក្ដីសំរេច

២៤-៣-១៩៩៩ -សេចក្ដីសំរេចលេខ ២៣៤ សសរ.មស.ក្រខ ស្ដីពីការបែងចែកនិស្សិតចំនួន ០១ នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស ៦២៥

២៤-៣-១៩៩៩ -សេចក្ដីសំរេចលេខ ២៣៥ សសរ.មស.ក្រខ ស្ដីពីការបែងចែកនិស្សិតចំនួន ០២ នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស ៦២៦

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧៥

**យើងព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់អនុក្រឹត្យលេខ ៣៧ អនក្រ.គត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំងក្រសួងការពារជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ត្រាស់បង្គាប់**

មាត្រា ១ .- ត្រូវបានតែងតាំងតម្លើងឋានន្តរសក្តិ និង ផ្លាស់ប្តូរមុខងារ នាយកទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលរាយនាមដូចខាងក្រោម ៖

ក-តែងតាំង និង ផ្លាស់ប្តូរមុខងារ

-ឧត្តមសេនីយ៍ទោ **គៀវ សាវុធ** អត្តលេខ ០០០០៣៥ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេសបច្ចុប្បន្នជាមេបញ្ជាការរង កងទ័ពជើងគោក

ខ-តែងតាំង និង តម្លើងឋានន្តរសក្តិជា ឧត្តមសេនីយ៍ទោ

-ឧត្តមសេនីយ៍ត្រី **សៅ សុខា** អត្តលេខ ០០០១០៥ មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេសបច្ចុប្បន្នជាមេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

ឧត្តមសេនីយ៍ត្រី **ណឹម សុវត្ថិ** អត្តលេខ ០០០០៦៩ បច្ចុប្បន្នជាអគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា ទទួលបន្ថែមលើមុខងារដែលមានស្រាប់

**មាត្រា ២ ._** នាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

**ជំរាបជូន**

សម្តេចនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

ព្រះហស្តលេខា ហត្ថលេខា នាយករដ្ឋមន្ត្រី

អ្នកអង្គម្ចាស់ ហត្ថលេខា

**ស៊ីសុវត្ថិ ស៊ីរីវុឌ្ឍ ទៀ បាញ់**

**ហ៊ុន សែន**

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

**អនុក្រឹត្យលេខ ៨៧ អនក្រ.តត**
**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សំរេច

**មាត្រា ១ ._** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការក្រៅរដ្ឋាភិបាល និងសប្បុរសជន ដែលបានបរិច្ចាគថវិកាជួយកសាងសាលារៀន នៅស្រុកកំពង់ត្របែក និងស្រុកបាភ្នំ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ ៖

១-អង្គការ J.S.R.C ឈ្មោះ SHIMPUKU JI TEMPLE បរិច្ចាគថវិកា ២៣.០០០ ដុល្លារអាមេរិក ។

២-លោកស្រី OSANAI MIEKO ប្រធានអង្គការ J.H.P បរិច្ចាគថវិកា ២៣.៦០០ ដុល្លារអាមេរិក ។

៣-ឯកឧត្តម ស្បោង សារ៉ាត អភិបាលរងទី៣ ខេត្តព្រៃវែង បរិច្ចាគថវិកា ១៨.៧០០ ដុល្លារអាមេរិក ។

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាល ខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៨ អនក្រ.តត
## ស្តីពីការ តែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- **យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងផែនការ**

សំរេច

**មាត្រា ១ ._** តែងតាំងមន្ត្រីរាជការ នៃក្រសួងផែនការដូចមានរាយនាមខាងក្រោម ៖

-លោក **ខួន ថាវរៈ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានផែនការ

-លោក នុត ចន្ទសុខា ជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

-លោក ឆាន់ លីណា ជាប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រ ជំរឿន និងអង្កេត

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨៩ អនក្រ.តត

## ស្តីពីការ តម្លើងឋានន្តរសក្តិ ជាកិច្ចបច្ឆាមរណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងការពារជាតិ

**សំរេច**

មាត្រា ១ ._ ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរសេនីយ៍ឯក** ជាកិច្ចបច្ឆាមរណៈជូនសព ៖

-លោកវរសេនីយ៍ទោ ម៉ម សុច្ចះ អត្តលេខ ០០១៣៦៧ នាយការិយាល័យរាចរ នាយកដ្ឋានអធិការកិច្ចទូទៅ ក្រសួងការពារជាតិ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## ២-សារាចរណែនាំ

រាជធានីភ្នំពេញ ,ថ្ងៃទី២៩ ខែមិនា ឆ្នាំ១៩៩៩

**សារាចរណែនាំ លេខ ០៣ សរ.ណន**
**ស្តីពីការរៀបចំបុណ្យចូលឆ្នាំថ្មី ឆ្នាំ ថោះ**
**ឯកស័ក ព.ស ២៥៤៣ គ.ស ១៩៩៩**

***

ជារៀងរាល់ឆ្នាំ ប្រជាពលរដ្ឋខ្មែរគ្រប់រូប ទាំងនៅទីក្រុង ទាំងនៅជនបទ តែងប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិរបស់ខ្លួន ក្នុងមនោសញ្ចេតនាសប្បាយរីករាយយ៉ាងក្រៃលេង ។

ពិធីបុណ្យប្រពៃណីជាតិដ៏សំខាន់នេះ ប្រារព្ធឡើង ដើម្បីសំដែងអំណរសាទរ ចំពោះការចូលមកដល់នៃឆ្នាំថ្មីសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ថ្វាយព្រះពរព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនិងសម្តេចព្រះរាជអគ្គមហេសីជាទីគោរពសក្ការៈ ថ្វាយព្រះពរ ជូនពរថ្នាក់ដឹកនាំរដ្ឋសភា និងរាជរដ្ឋាភិបាល ព្រមទាំងចំពោះបុព្វការីជន មានមាតាបិតាជាដើម និង បង្កើតមនោសញ្ចេតនាមហាសាមគ្គី ជាភាតរភាព រួបរួមគ្នាដោយការជួបជុំកំសាន្តសប្បាយទទួលសព្ទសាធុការពរទេវតាឆ្នាំថ្មី តាមប្រពៃណីរបស់ជាតិ ក្រោយបានបញ្ចប់ការបែនបោកប្រមូលផលស្រូវនាឆ្នាំចាស់ និងមុនការចាប់ផ្តើមបង្កបង្កើនផលនាឆ្នាំថ្មី ដែលនឹងត្រូវដំណើរការក្នុងវស្សានរដូវខាងមុខ ។

ឆ្នាំនេះ ពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំថោះ ឯកស័ក ព.ស ២៥៤៣ គ.ស ១៩៩៩ នឹងប្រព្រឹត្តទៅ ៣ ថ្ងៃ គឺ :

-ថ្ងៃ ពុធ ១៤ រោច ខែ ចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ ១៩៩៩ វេលាម៉ោង ១១ និង ១២ នាទី ថ្ងៃត្រង់ ជាថ្ងៃចូលឆ្នាំ ។

-ថ្ងៃ ព្រហស្បតិ៍ ១ កើត ខែពិសាខ ត្រូវនឹងថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៩៩ ជាវារៈវនប័ត ។

-ថ្ងៃ សុក្រ ២ កើត ខែ ពិសាខ ត្រូវនឹងថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៩៩ ជាវារៈឡើងស័ក គឺផ្លាស់ ស័កថ្មី នៅថ្ងៃនេះគំរប់ជាសង្ក្រាន្ត ៣ ថ្ងៃ ដោយបរិបូណ៌ ចូលជាសកលឆ្នាំ ថោះ ឯកស័ក ត រៀងទៅ ។

ដើម្បីបង្កការសប្បាយរីករាយនិងរក្សាប្រពៃណីទំនៀមទំលាប់របស់ជាតិ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមដាក់ចេញសារាចរណែនាំដូចតទៅនេះ ÷

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ខេត្ត-ក្រុង គ្រប់វត្តអារាម សាលារៀន អង្គភាព រោងចក្រសហគ្រាស និង គ្រប់គេហដ្ឋាន ត្រូវរៀបចំសំអាតតុបតែងលំអ ដោយមានបដាពាក្យស្លោកទង់ជាតិ អោយបានស្របទៅនឹងប្រពៃណីទំនៀមទំលាប់របស់ជាតិ និងរៀបចំគ្រឿងសក្ការៈបូជា មានផ្កាភ្ញីជាដើម ថ្វាយព្រះរតនត្រ័យ និងរៀបចំពលិការដ៏សមរម្យ មាននំចំណី ផ្លែឈើជាដើមទទួលស្វាគមន៍ចំពោះទេវតាឆ្នាំថ្មី ។ ពេលយប់នៅរាជធានីភ្នំពេញ និងនៅទីរួមខេត្ត-ក្រុង ខ័ណ្ឌទីប្រជុំជន

គប្បីគុបតែងលំអ ដោយភ្លើងអគ្គិសនី និងនៅជនបទដុតគោម ប្រទីបផ្កាឈើអោយបានភ្លឺព្រោងព្រាតរៀងរាល់យប់ ។

២-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវណែនាំដល់មន្ទីរវប្បធម៌ខេត្ត-ក្រុង អោយសំដែងសិល្បៈ ជូនប្រជារាស្ត្រទស្សនាកំសាន្តតាមទីធ្លាសាធារណៈ និងបំផុសចលនាប្រជាពលរដ្ឋចូលរួមអោយបានផុសផុល ក្នុងការចាត់តាំងពិធីលេងល្បែងប្រជាប្រិយ៍របស់ជាតិ ដូចជាចោលឈូងបោះអង្គុញ ទាញព្រ័ត្រ ទាត់សី លោតកន្សែង រាំកំសាន្តសប្បាយតាមទីកន្លែងដែលមានប្រាសាទបុរាណ មានរមណីយដ្ឋាន តាមទីប្រជុំជន តាមភូមិ តាមចំណង់ចំណូលចិត្ត និងទំនៀមទំលាប់របស់តំបន់នីមួយៗ ។

៣-ក្រសួងធម្មការនិងសាសនា សហការជាមួយអាជ្ញាធរខេត្ត-ក្រុង ត្រូវណែនាំដល់ អង្គភាពធម្មការ ក្នុងឱវាទរៀបចំពិធីការសាសនា តាមវត្តអារាមនីមួយៗអោយបានសមស្របតាម ប្រពៃណីសាសនា និង ប្រពៃណីជាតិ និងបង្កលក្ខណៈអោយពុទ្ធបរិស័ទ ទាយក ទាយិកាគ្រប់រូបបានបំពេញបុណ្យកុសល ក្នុងឱកាសចូលឆ្នាំថ្មី ៣ ថ្ងៃដោយសប្បាយរីករាយ ។ អ្វីដែលជាប្រពៃណីជាតិ ដ៏ល្អប្រណីតគួររំលឹកឡើងវិញ ដើម្បីបង្ហាញអោយយុវវ័យជំនាន់ក្រោយបានឃើញច្បាស់ និងបន្តថែរក្សាអោយបានគង់វង្ស ។

៤-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាពក្រោមឱវាទ គ្រប់ខេត្ត-ក្រុង ត្រូវបង្កើតកិច្ចការពារថែរក្សាសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់សង្គមដោយបង្កលក្ខណៈប្រគេនព្រះសង្ឃ ជូនពុទ្ធបរិស័ទ និងប្រជាពលរដ្ឋយើង រៀបចំពិធីបុណ្យចូលឆ្នាំថ្មីនេះបានសប្បាយរីករាយ និងធានាសុវត្ថិភាព ។

៥-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ ត្រូវរៀបចំកម្មវិធីណែនាំដល់ក្រសួងរដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព ខេត្ត-ក្រុង និងសមាគម អង្គការក្រៅរដ្ឋាភិបាលនានា ចាត់តាំងគណៈប្រតិភូ និងបំផុសអំពាវនាវសប្បុរសជនអោយជួយឧបត្ថម្ភអំណោយជាសម្ភារៈថវិកាចុះសួរសុខទុក្ខអ្នកមានជម្ងឺ របួស កំពុងសំរាកព្យាបាលនៅមន្ទីរពេទ្យ និងអ្នកពិការនៅតាមមជ្ឈមណ្ឌលយុទ្ធជនពិការ កុមារកំព្រា ចាស់ព្រឹទ្ធាចារ្យ ឥតមានទីពុំនាក់ ដើម្បីជាការលើកទឹកចិត្ត និងបង្កើនស្មារតីសាមគ្គីជួយគ្នាទៅវិញទៅមកក្នុងគ្រាទុក្ខលំបាក ក៏ដូចជាក្នុងគ្រាសប្បាយរីករាយ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសង្ឃឹមថា គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋានគ្រប់ស្ថាប័នអង្គភាព និងគ្រប់ខេត្ត-ក្រុង ទទួលអនុវត្តស្មារតីសារាចរណែនាំនេះ សំរេចបានលទ្ធផលល្អប្រសើរ ។

ជ.រាជរដ្ឋាភិបាល
ឧបនាយករដ្ឋមន្ត្រី
ស ខេង

## ពាក្យស្លោក
## សំរាប់ប្រើប្រាស់ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំ ថោះ
## ឯកស័ក ព.ស ២៥៤៣ គ.ស ១៩៩៩

***

១- សួស្តី ឆ្នាំថ្មី !

២- សូមជូនពរឆ្នាំថ្មី សិរីសួស្តីជ័យមង្គល និង វិបុលសុខគ្រប់ប្រការ

៣- សូមប្រសិទ្ធពរជ័យបវរមហាប្រសើរក្នុងឱកាសចូលឆ្នាំថ្មី

៤- ឆ្នាំថ្មី ភារកិច្ចថ្មី ជ័យជំនះថ្មី !

៥- សូមថ្វាយព្រះពរ សម្តេចឪ សម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ

៦- ជយោ ! សម្តេចព្រះបិតាឯករាជ្យជាតិ

៧- ជយោ ! សម្តេចព្រះបិតាបង្រួបបង្រួម និងផ្សះផ្សាជាតិ

៨- ជយោ ! ព្រះរាជាណាចក្រកម្ពុជា

៩- ជាតិ សាសនា ព្រះមហាក្សត្រ

១០-ជយោ ! សន្តិភាព និង ការអភិវឌ្ឍន៍

១១- ជយោ ! រាជរដ្ឋាភិបាល សេដ្ឋកិច្ច

១២- សន្សំថៃ គឺស្នេហាជាតិ

១៣-ប្តេជ្ញា បំបាត់ភាពអនាធិបតេយ្យ ការបំផ្លាញព្រៃឈើ

****

រាជធានីភ្នំពេញ,ថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩

## សារាចរណែនាំលេខ ០៤ សរណន
## ស្តីពីការរៀបចំបុណ្យវិសាខបូជា
## និងព្រះរាជពិធីច្រត់ព្រះនង្គ័ល

***

* បុណ្យវិសាខបូជា គឺជាបុណ្យមួយយ៉ាងធំក្នុងព្រះពុទ្ធសាសនា ដែលប្រទេសកាន់ព្រះពុទ្ធសាសនាទាំងអស់លើសកលលោក តែងប្រារព្ធធ្វើពុំដែលខាន ។

ពិធីនេះ ប្រព្រឹត្តឡើងដើម្បីរំលឹកដល់ថ្ងៃជាមហាមង្គលទាំងបី ដែលព្រះសម្មាសម្ពុទ្ធបរមគ្រូ ទ្រង់ប្រសូតចាកឧទរមាតាផង ទ្រង់ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណផង និងទ្រង់រំលត់ខ័ន្ធចូលកាន់ព្រះបរមនិព្វានផង ។

ចំពោះពុទ្ធសាសនិកខ្មែរយើង ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ក៏តែងតែប្រារព្ធពិធីបុណ្យវិសាខបូជាជារៀងរាល់ឆ្នាំ នៅគ្រប់វត្តអារាម ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយចាត់ទុកថា ជាមហា

កុសលដ៏ប្រសើរ ។ រីឯរាជរដ្ឋាភិបាល ក៏បានចាត់តាំងរៀបចំពិធីបុណ្យវិសាខបូជាជាផ្លូវការ នៅបរិវេណព្រះសក្យមុនីចេតិយ៍ មុខស្ថានីយ៍រថភ្លើង ដោយមានថ្នាក់ដឹកនាំរដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ អ្នកមុខ អ្នកការ ពុទ្ធបរិស័ទ ចូលរួមដ៏ច្រើនកុះករ សមស្របទៅនឹងស្មារតីរដ្ឋធម្មនុញ្ញដែលបានកំណត់ថា “ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ” ។

ឆ្នាំនេះ វិសាខបូជា នឹងត្រូវប្រព្រឹត្តទៅរយៈពេល ២ ថ្ងៃ គឺថ្ងៃ ១៥កើត និង ១រោច ខែពិសាខ ព.ស ២៥៤៣ ត្រូវនឹងថ្ងៃទី ២៩ និងទី៣០ ខែមេសា ឆ្នាំ ១៩៩៩ តាមកម្មវិធីជាក់ស្តែង ។

* ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាព្រះរាជបវេណីដ៏សំខាន់ក្នុងបណ្តាព្រះរាជពិធីទ្វាទសមាសប្រចាំឆ្នាំចាត់ទុកថា ជាមង្គលមួយដ៏ប្រសើររបស់ប្រជារាស្ត្រខ្មែរ ហៅថា វប្បមង្គល ដែលព្រះមហាក្សត្រគ្រប់ព្រះអង្គតែងដឹកនាំប្រជារាស្ត្រប្រារព្ធធ្វើពុំដែលលស់ខាន តាំងពីបូរាណកាលមក ។ ព្រះរាជពិធីនេះ ប្រព្រឹត្តឡើង ដើម្បីជាមង្គលឧទ្ទិសដល់ការធ្វើស្រែចំការ ឲ្យបង្អុរទឹកភ្លៀងបរិបូណ៌តាមរដូវកាលអាចបំពេញផលកិកម្មកសិកម្មទទួលបានលទ្ធផលខ្ពស់របស់ប្រជាកសិករយើង ។

ឆ្នាំនេះ ព្រះរាជពិធីច្រត់ព្រះនង្គ័ល នឹងត្រូវប្រព្រឹត្តទៅរយៈពេល ៤ ថ្ងៃ គឺថ្ងៃ ១-២-៣ រោច ខែពិសាខ ត្រូវនឹងថ្ងៃទី ៣០ មេសា និងថ្ងៃទី១-២ ឧសភា ជាទិវាតាំងពិធីច្រត់ព្រះនង្គ័ល ជាភារកិច្ចរបស់លោកអាចារ្យ និងក្រុមបារគូ ។ ឯថ្ងៃ ៤រោច ខែពិសាខ ត្រូវនឹងថ្ងៃទី ៣ ខែឧសភា ១៩៩៩ ជាព្រះរាជពិធីច្រត់ព្រះនង្គ័លផ្លូវការ ។

ដើម្បីញ៉ាំងពិធីទាំងនេះ ឲ្យប្រព្រឹត្តទៅឧឡារិក អធិកអធម សមស្របតាមអត្ថន័យ និង ខ្លឹមសារដូចពោលខាងលើ រាជរដ្ឋាភិបាល សូមដាក់ចេញសារាចរណែនាំ ដូចតទៅនេះ ៖

**I-អំពីបុណ្យវិសាខបូជា ៖**

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ និងអន្តរជាតិ ត្រូវសហការជាមួយក្រសួងធម្មការ និងសាសនា និង សាលាក្រុងភ្នំពេញ ចាត់តាំងពិធីបុណ្យវិសាខបូជាជាផ្លូវការ នៅបរិវេណព្រះសក្យមុនីចេតិយ៍មុខស្ថានីយ៍រថភ្លើង ដោយមានអញ្ជើញថ្នាក់ដឹកនាំ និង សមាជិកសមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ និងពុទ្ធបរិស័ទ ចូលរួមឲ្យបានច្រើនកុះករតាមកម្មវិធីជាក់ស្តែង ។

-ក្រសួងធម្មការនិងសាសនា ត្រូវធ្វើការណែនាំទៅអង្គភាពក្រោមឱវាទ ឲ្យចាប់អារម្មណ៍ យកចិត្តទុកដាក់ក្រើនរំលឹកចំពោះពុទ្ធបរិស័ទ ឲ្យរៀបចំពិធីបុណ្យវិសាខបូជានៅតាមវត្តអារាមនីមួយៗ ឲ្យបានផុសផុល ដើម្បីលើកកំពស់ឥទ្ធិពលព្រះពុទ្ធសាសនា និងប្រពៃណីដ៏ល្អរបស់ជាតិ ។

-ក្រសួងព្រះបរមរាជវាំង ចាត់តាំងព្រះរាជពិធីនៅក្នុងព្រះបរមរាជវាំង តាមព្រះរាជបវេណី និងតាមការសព្វព្រះរាជហឫទ័យរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះរាជអគ្គមហេសីជាទី គោរពសក្ការៈ ។

II-អំពីព្រះរាជពិធីច្រត់ព្រះនង្គ័ល :

-ក្រសួងព្រះបរមរាជវាំង ដោយមានការចូលរួមពីគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និង អន្តរជាតិ សាលាក្រុងភ្នំពេញនិងក្រសួងពាក់ព័ន្ធ ចាត់តាំងព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅទីព្រះស្រែ វាលព្រះមេរុឲ្យបានឧឡារិកអធិកអធម ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈ ដោយមានការចូលរួមពីព្រះរាជវង្សានុវង្ស ថ្នាក់ដឹកនាំ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការ និងប្រជារាស្ត្រ តាមចំនួនកំណត់ជាក់ស្តែង ដោយរក្សាឲ្យបានគង់វង់នូវព្រះរាជបវេណីពីបូរាណរបស់ព្រះអតីតបរមក្សត្រនៃយើង ។

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចាត់តាំងក្រុមសិល្បៈ សំដែងជូនមហាជនទស្សនាអបអរសាទរព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៩៩៩ នៅទីវាលព្រះស្រែ វាលព្រះមេរុ ។

-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ សហការការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ សង្គម ចរាចរ ធានាសុវត្ថិភាពឲ្យបានល្អ ។

-ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសម្ភារៈ ថវិកា សម្រាប់បំរើពិធីបុណ្យទាំងពីរ ឲ្យប្រព្រឹត្តទៅស្របតាមគោលបំណង និងសំណូមពរ ។

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន សាលាក្រុងភ្នំពេញ ត្រូវចាត់តាំងមន្ត្រីរាជការក្រោមឱវាទតាមចំនួនកំណត់ ចូលរួមក្នុងពិធីបុណ្យទាំងពីរឲ្យបានឧឡារិក អធិកអធម ។ ដោយឡែកខេត្ត-ក្រុង ត្រូវបំផុសឲ្យចងបដា ពាក្យស្លោក ទង់ជាតិ អបអរសាទរបុណ្យទាំងពីរខាងលើឲ្យបានអធិកអធម ជាទិវាបុណ្យជាតិមួយដ៏រុងរឿង ។

ទទួលបានសារាចរណែនាំនេះ រាជរដ្ឋាភិបាលសង្ឃឹមថា គ្រប់ក្រសួង - គ្រប់រដ្ឋលេខាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធ នឹងចាត់តាំងអនុវត្តសម្រេចបានលទ្ធផលល្អប្រសើរ ។

ជ.រាជរដ្ឋាភិបាល
ឧបនាយករដ្ឋមន្ត្រី
ស ខេង

***

## ពាក្យស្លោកសំរាប់ទិវាច្រត់ព្រះនង្គ័ល

***

១- អបអរសាទរ ព្រះរាជពិធីច្រត់ព្រះនង្គ័ល " ០៣-៥-៩៩ "

២- ជយោ ! សម្តេចព្រះបិតាកសិកម្មជាតិ

៣- កសិកម្ម ជាមូលដ្ឋាននៃសេដ្ឋកិច្ចជាតិ

៤- អភិវឌ្ឍន៍វិស័យកសិកម្ម គឺអភិវឌ្ឍន៍សង្គមជាតិ
៥- កសិកម្មលូតលាស់ ជីវភាពប្រជាកសិករីកចំរើន
៦- រួមគ្នាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម
៧- ព្រះរាជពិធីច្រត់ព្រះនង្គ័ល ជាវប្បមង្គលដ៏ឧត្តម
៨- សូមថ្វាយព្រះពរ សម្តេចឪ សម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ

### ពាក្យស្លោកសំរាប់បុណ្យវិសាខបូជា

***

- សូមថ្វាយព្រះពរសម្តេចឪ សម្តេចម៉ែ ជាទីគោរពសក្ការៈ
- ជយោ ! ព្រះរាជាណាចក្រកម្ពុជា
- ជាតិ សាសនា ព្រះមហាក្សត្រ
- ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ
- នត្ថិ សន្តិ បរំ សុខំ គ្មានសុខអ្វីស្មើនឹងសេចក្តីស្ងប់
- សុខោ បុញ្ញស្ស ឧច្ចយោ ការសន្សំបុណ្យនាំមកនូវសេចក្តីសុខ
- អហឹង្សា ជាគោលការណ៍រួមនៃពុទ្ធសាសនា
- សុភមង្គល និងអភិវឌ្ឍន៍ ជាសំណូមពរដ៏ពិសិដ្ឋរបស់ពុទ្ធសាសនា
- សូមព្រះធម៌របស់ព្រះពុទ្ធបរមគ្រូជ្រួតជ្រាបគ្រប់មនុស្សទូទៅ
- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍

★★★

# III- ការងាររបស់ក្រសួង

## ១-ទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩

### ប្រកាសលេខ ៤២ ប្រក
### ស្តីពីការតែងតាំងមន្ត្រីរាជការ
### ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

**សំរេច**

**ប្រការ ១ :** តែងតាំងលោក ម៉ី អូយ ជាជំនួយការ អមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងាររាជកិច្ចមានឋានៈស្មើ **ប្រធានការិយាល័យ** ។

**ប្រការ ២ :** ប្រធាននាយកដ្ឋានរដ្ឋបាល-បុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានកុំព្យូទ័រ ព្រមទាំង សាមីខ្លួនមានភារកិច្ច អនុវត្តសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សុខ អាន**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៤៣ ប្រក
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញអនុក្រឹត្យលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

**សំរេច**

**ប្រការ ១ :** តែងតាំងលោក **កែវ អូម** ជាជំនួយការ អមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងាររោងពុម្ពរាជកិច្ច មានឋានៈស្មើ **ប្រធានការិយាល័យ** ។

**ប្រការ ២ :** ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានសេវាកម្មកុំព្យូទ័រ ព្រមទាំង សាមីខ្លួនមានភារកិច្ច អនុវត្តសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សុខ អាន**

***

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមីនា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ១១១ ប្រក.សហវ.រតន**

**ស្តីពីការបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យរបស់រដ្ឋ**

**ទេសរដ្ឋមន្ត្រី**

***

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៦ ស្តីពីច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៥/១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ស្តីពី បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៩ ប្រក.សហវ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីប្រព័ន្ធ គណនី នៃគណនេយ្យ នៅរតនាគារជាតិ
- យោងការចាំបាច់ នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បច្ចុប្បន្ន

**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតបន្ថែមនូវអនុគណនី ចំនួន ០៣ ដែលមានឈ្មោះ និង លេខសំគាល់ដូចខាងក្រោម :

១-អនុគណនី " បេឡាពិសេសសំរាប់បើកផ្តល់ប្រាក់ម៉ោង និង ប្រាក់បេសកកម្ម របស់បុគ្គលិកសិក្សា " ដែលមានលេខសំគាល់ " ៥៣២.២ " ។

២-អនុគណនី " ប្រាក់បញ្ញើរបស់ភ្នាក់ងារបើកផ្តល់ក្រសួងអប់រំយុវជន និងកីឡា អំពីប្រាក់ម៉ោងបុគ្គលិកសិក្សា " ដែលមានលេខសំគាល់ " ៤៥០.១៦ " និងវិភាគតាមលំដាប់ថ្នាក់បន្តបន្ទាប់ ។

៣-អនុគណនី " បណ្តេបេឡាត្រូវសងសំរាប់ប្រាក់បេសកកម្មបុគ្គលិកសិក្សា " ដែលមានលេខសំគាល់ " ៤៧៣.១៦ " និង វិភាគតាមលំដាប់ថ្នាក់បន្តបន្ទាប់ ។

**ប្រការ ២ :** អនុគណនី ទាំងបីខាងលើនេះ សំរាប់វិភាគបន្ថែមលើ គណនីដើម ដែលមានលេខសំគាល់ : " ៥៣២ " " ៤៧៣ " និង " ៤៥០ " ។

-ចំពោះប្រព្រឹត្តិកម្ម នៃអនុគណនីទាំងបីនេះ គឺមានលក្ខណៈដូចគ្នានឹងគណនីដើមដែរ ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធានរតនាគារជាតិ និង បណ្តាអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

**ប្រការ ៤ :** ប្រកាសនេះមានតំលៃអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

**គាត ឈន់**

★★★

## ៣-នីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមិនា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៣៥៩ ឧក.ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទ សម្ដេច **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិត ៤៨០ /៩៩ គ.វ.ក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ១៣៨ សណ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ របស់សាលាខេត្តកណ្ដាល
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ជា ស៊ីណាត ហ្គាមេន ខូ អិលធីឌី ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ១៩៩៩

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុម ជា ស៊ីណាត ហ្គាមេន ខូអិលធីឌី ( CHEA SINAT GARMENT CO., LTD ) តំណាងដោយលោកស្រី ជាស៊ីណាត សញ្ជាតិ កម្ពុជា ភេទស្រី អាយុ ៣៩ ឆ្នាំ អាសយដ្ឋាន ផ្ទះលេខ ២០៤ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ២៣៨៧៥០ ភព ចុះថ្ងៃទី១០-៨-១៩៨៩ បង្កើត “ រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ” ដែលមានឈ្មោះថា “ រោងចក្រកាត់ដេរ ជា ស៊ីណាត ហ្គាមេន ” មានទីតាំងស្ថិតនៅ ភូមិក្បាលជ្រោយ ឃុំព្រែកឯង ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ក្នុងពិធីដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " កាត់ -ដេរ សំលៀកបំពាក់ " ទៅតាមគំរូដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្មពី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង ប្រធានក្រុមហ៊ុន ជាស៊ីណាត ហ្គាមេន ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស៊ុយ សែម

★★★

## ៤-និស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៩៩

### ប្រកាសលេខ ០៧៧ បឌ.ប្រក

### ស្តីពីការ តម្លើងតួនាទី និងតែងតាំង មន្ត្រីរាជការ

***

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឲ្យប្រើដោយច្បាប់ស្តីពីការ បង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- យោងតាមសំណើ របស់នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី១០-០៣-៩៩
- បានឃើញការងារចាំបាច់របស់ក្រសួង

សំរេច

**ប្រការ ១ :** ត្រូវបានតម្លើងតួនាទី និងតែងតាំងមន្ត្រីរាជការចំនួន ០៤រូប ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធានមជ្ឈមណ្ឌល ប្រធានការិយាល័យ និង អនុប្រធានការិយាល័យ នៃ នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ដូចមានរាយនាមខាងក្រោម ៖

១-អ្នកស្រី **សៅ សុវត្ថា** អនុប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ទទួលបន្ទុកមជ្ឈមណ្ឌលវិទ្យុចល័ត ។

២-លោក **ហ៊ាន ជាវុធដា** ប្រធានមជ្ឈមណ្ឌលសម្របសម្រួលប្រព័ន្ធ

៣-លោក **ស ធូរី** ប្រធានការិយាល័យទំនាក់ទំនងអន្តរជាតិ

៤-លោក **ឆែម ឆេន** អនុប្រធានការិយាល័យរដ្ឋបាល

**ប្រការ ២ :** មន្ត្រីរាជការដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវអនុវត្តន៍តាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ ៣ :** ខុទ្ទកាល័យ , អធិការដ្ឋាន នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះ ។

**ប្រការ ៤ :** រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សូ ឃុន**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ០៧៨ ប.ទ.ប្រក

## ស្តីពីការ តម្លើងតួនាទី និងតែងតាំង មន្ត្រីរាជការ

***

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើអោយច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញលិខិតលេខ ០០២/៩៩ នទនិ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ ១៩៩៩ របស់នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ
- យោងតាមសំណើ របស់នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី១០-០៣-៩៩
- បានឃើញការងារចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ត្រូវបានតម្លើងតួនាទី និងតែងតាំងមន្ត្រីរាជការចំនួន ០២រូប ថ្នាក់អនុប្រធាននាយកដ្ឋាននិង ប្រធានមជ្ឈមណ្ឌល នៃនាយកដ្ឋានទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ ដូចមានរាយនាមខាងក្រោម ៖

១-លោក **ម៉ូវ ចរិយា** អនុប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ ទទួលបន្ទុកផ្ទាល់មជ្ឈមណ្ឌលពត៌មានវិទ្យា

២-លោក **ជិន ដារ៉ូ** ប្រធានមជ្ឈមណ្ឌល ពត៌មានវិទ្យា

**ប្រការ ២ :** មន្ត្រីរាជការដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវអនុវត្តន៍តាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ ៣ :** ខុទ្ទកាល័យ , អធិការដ្ឋាន នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ នាយកដ្ឋាននយោបាយ ទូរគមនាគមន៍និយ័ត អន្តរជាតិ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះ ។

**ប្រការ ៤ :** រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សូ ឃុន**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ០៧៩ មខ.ប្រក
## ស្តីពីការ តែងតាំង មន្ត្រី បុគ្គលិក រាជការ

***

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើអោយច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើ របស់នាយកដ្ឋានផែនការគននេយ្យ ហិរញ្ញវត្ថុ
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី១០-០៣-៩៩
- បានឃើញការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** ត្រូវបានតែងតាំងលោក **ឃុន ទ៉ា** ជាអនុប្រធានការិយាល័យទស្សនាវដ្តី នៃនាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ ។

**ប្រការ ២ :** មន្ត្រីរាជការដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវអនុវត្តន៍តាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ។

**ប្រការ ៣ :** ខុទ្ទកាល័យ , អធិការដ្ឋាន នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះ ។

**ប្រការ ៤ :** រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**សូ ឃុន**

***

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៩៩

# ប្រកាសលេខ ៨០ មឧ.ប្រក

## ស្តីពីការ តម្លើងតួនាទី និងតែងតាំង មន្ត្រីរាជការ

***

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើអោយច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើ របស់នាយកដ្ឋាន ទូរគមនាគមន៍ក្នុងប្រទេស
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី១០-០៣-៩៩
- បានឃើញការងារចាំបាច់របស់ក្រសួង

## សំរេច

ប្រការ ១ : ត្រូវបានតម្លើងតួនាទី និងតែងតាំងមន្ត្រីរាជការចំនួន ០៧រូប ថ្នាក់អនុប្រធាននាយកដ្ឋាន ប្រធានមជ្ឈមណ្ឌល អនុប្រធានមជ្ឈមណ្ឌល នៃនាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស ដូចមានរាយនាមខាងក្រោម ៖

១-លោក ឧង ម៉ូរ៉ែង អនុប្រធាននាយកដ្ឋានក្នុងប្រទេសទូរគមនាគមន៍ ទទួលបន្ទុកបណ្តាញកាប្លិ៍ខាងក្រៅ ។

២-លោក ចូច ឡេង ប្រធានមជ្ឈមណ្ឌល បណ្តាញខាងក្រៅ ( OSP )

៣-លោក ពៅ ពិទូរ្យ អនុប្រធានមជ្ឈមណ្ឌល បណ្តាញខាងក្រៅ ( OSP )

៤-លោក នឹម ចំរ៉ានី អនុប្រធានមជ្ឈមណ្ឌល បណ្តាញខាងក្រៅ ( OSP )

៥-លោក ទ៉ិច ឫទ្ធី ប្រធានមជ្ឈមណ្ឌល ( AXE )

៦-លោក សុខ ផុន អនុប្រធានមជ្ឈមណ្ឌល ( AXE )

៧-លោក ស៊ុន ចំរើន ប្រធានមជ្ឈមណ្ឌល ( Alcatel )

ប្រការ ២ : មន្ត្រីរាជការដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវអនុវត្តន៍តាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ។

ប្រការ ៣ : ខុទ្ទកាល័យ , អគ្គនាយកដ្ឋាន នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តន៍តាមខ្លឹមសារ នៃប្រកាសនេះ ។

ប្រការ ៤ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

សូ យុន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៨១ បន.ប្រក

## ស្តីពីការ បង្កើតមជ្ឈមណ្ឌលវិទ្យុ ចល័ត

***

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើអោយច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើដោយច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើ របស់នាយកដ្ឋាន ទូរគមនាគមន៍អន្តរជាតិ
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួងនា ចុះថ្ងៃទី១០-០៣-៩៩
- បានឃើញការងារចាំបាច់របស់ក្រសួង

## សំរេច

ប្រការ ១ : ត្រូវបានបង្កើតតួនាទី មជ្ឈមណ្ឌលវិទ្យុ ចល័ត ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ ។

ប្រការ ២ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ នាយកដ្ឋានប្រៃសណីយ៍ នាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុទូរគមនាគមន៍ និង អាជ្ញាប័ណ្ណ ត្រូវអនុវត្តន៍តាមខ្លឹមសារនៃប្រកាសនេះ ។

ប្រការ ៣ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

សូ ឃុន

★★★

## ៥-ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៩

### ប្រកាសលេខ ១២៥ សក.បយ

### ស្តីពីការអនុញ្ញាតអោយក្រុមហ៊ុន ខេមម៉ាស់ ខូអិលធីឌី ( CAMMAS.CO., LTD) ធ្វើការរៀបចំ និងដំណើរការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី

***

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

- តាមសំណើរបស់ក្រុមហ៊ុន ខេមម៉ាស់ ខូអិលធីឌី ( CAMMAS.CO.,LTD ) ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩

**សំរេច**

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ខេមម៉ាស់ ខូអិលធីឌី (CAMMAS.CO.,LTD) ដែលមានឧកញ៉ា អ៊ូស្មាន ហាស្សាន់ជាអ្នកតំណាង សញ្ជាតិខ្មែរ អត្តសញ្ញាប័ណ្ណលេខ ១២៩៧៨២ ភព ធ្វើនៅរាជធានីភ្នំពេញ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ១៩៩១ ទីតាំងក្រុមហ៊ុនស្ថិតនៅផ្ទះលេខ ១៤៥ អឺសូន្យ ផ្លូវលេខ ១៩៦ ក្រុមទី ៨ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញសហការជាមួយ ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីធ្វើការងាររៀបចំ ការបណ្តុះបណ្តាល និងការបញ្ជូន ពលករខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។

ប្រការ ២ : កំណត់អោយក្រុមហ៊ុន ខេមម៉ាស់ ខូ អិលធីឌី (CAMMAS.CO.,LTD) តំកល់ប្រាក់ធានាចំនួន ៣០.០០០ ដុល្លារអាមេរិក ( សាមសិបពាន់ ) ក្នុងគណនីរបស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានៅធនាគារពាណិជ្ជកម្មក្រៅប្រទេស ស្ថិតនៅផ្ទះលេខ២២៤ ផ្លូវនរោត្តម សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ យ៉ាងយូរប្រាំពីរថ្ងៃក្រោយចេញប្រកាស ។

នៅពេលដែលក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានជូនដំណឹងអំពីការទទួលបានកូតា ( Quota ) ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ខាងលើនេះហើយ ក្រុមហ៊ុនត្រូវយកប្រាក់មកតំកល់បន្ថែម ៧០.០០០ ដុល្លារអាមេរិក ( ចិតសិបពាន់) ទៀតអោយបានគ្រប់ ១០០.០០០ ដុល្លារអាមេរិក ( មួយរយពាន់ ) តាមគោលការណ៍ ក្នុងរយៈពេលមិនលើសពី ៧ ( ប្រាំពីរថ្ងៃ ) ចាប់ពីថ្ងៃដែលបានផ្តល់ដំណឹងនេះតទៅ ។ ក្នុងករណីដែលក្រុមហ៊ុនមិនបានតំកល់ប្រាក់បង្គ្រប់ តាមការកំណត់នេះទេ ប្រកាសនេះត្រូវបានចាត់ទុកជាមោឃៈដោយពេញច្បាប់ ។

ប្រការ ៣ : ក្រោយបានបង់ប្រាក់គ្រប់គ្រាន់តាមប្រការ២ ខាងលើនេះហើយ ក្រុមហ៊ុនត្រូវចុះកិច្ចព្រមព្រៀងមួយជាមួយក្រសួង ស្តីពីកិច្ចសហការគ្នារវាងក្រសួង និង ក្រុមហ៊ុន ក្នុងការរៀបចំ ការបញ្ជូន ការគ្រប់គ្រងពលករខ្មែរ ដែលទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។

ប្រការ ៤ : ក្រោយពីបានអនុវត្តត្រឹមត្រូវតាមប្រការ ២ និងប្រការ ៣ ក្រុមហ៊ុន ខេមម៉ាស់ ខូអិលធីឌី ( CAMMAS.CO.,LTD ) :

- ចាប់ពីពេលនេះតទៅ អាចចាប់ដំណើរការរាល់ការងាររៀបចំទាំងឡាយដែលជាប់ទាក់ទងនឹងការជ្រើសរើស ការបណ្តុះបណ្តាល និងការបញ្ជូនពលករខ្មែរ ដែលជាបន្ទុកចំណាយរបស់ក្រុមហ៊ុន ។

- រាល់ការផ្សព្វផ្សាយជាសាធារណៈស្តីពីការជ្រើសរើស និងបញ្ជូនពលករត្រូវតែមានការឯកភាពពីក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទាជាមុនសិនទើបអនុវត្តបាន ។
- ត្រូវរៀបចំ បណ្តុះបណ្តាល និង បញ្ជូនទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ទៅតាមប្រភេទនិងចំនួនពលករដែលក្រសួងកំណត់អោយដោយផ្អែកទៅលើ កូតា ( Quota ) ដែលប្រទេសនេះផ្តល់អោយសម្រាប់ប្រទេសកម្ពុជា ។

ប្រការ ៥ : ប្រកាសនេះមានសុពលភាពត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០១ ។ ក្រុមហ៊ុននេះត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរស្នើសុំធ្វើការពន្យាពេលប្រើប្រាស់ប្រកាសអនុញ្ញាតបន្តទៅទៀត អោយបានពីរខែយ៉ាង តិចមុនប្រកាសអនុញ្ញាតអស់សុពលភាព ឬ មួយស្នើសុំរៀបចំប្រកាសថ្មី ។ ក្នុងករណីដែលពិនិត្យឃើញថា ក្រុមហ៊ុន ខេមម៉ាស់ ខូអិលធីឌី ( CAMMAS.CO.,LTD ) អនុវត្តផ្ទុយនឹងច្បាប់ ឬ វិធាននានានៃព្រះរាជាណាចក្រកម្ពុជា និង អនុក្រឹត្យលេខ ៥៧ អនក្រ.បក របស់រាជរដ្ឋាភិបាល និងខ្លឹមសារប្រកាសនេះ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬ បដិសេធប្រកាសនេះទៅតាមករណីជាក់ស្តែង ។

ប្រការ ៦ : ប្រកាសនេះមានសុពល ចាប់ពីថ្ងៃដែលបានចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
អ៊ិត សំហេង

★★★

## ៦-និស្តីការរដ្ឋមន្ត្រីក្រសួង ពេសចរណ៍

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៩

### ប្រកាសលេខ ១២ ប្រក
### ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍
- យោងប្រកាសលេខ ១៩៥ កទច.ប្រក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៧ របស់ក្រសួងទេសចរណ៍ ស្តីពីតួនាទីភារកិច្ច និង រចនាសម្ព័ន្ធរបស់មន្ទីរទេសចរណ៍ខេត្ត-ក្រុង
- តាមសំណើលេខ ០៣៧/៩៩ ណអខ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៩ របស់អភិបាលខេត្តរតនគិរី
- តាមសំណូមពរភារកិច្ចចាំបាច់

**សំរេច**

**ប្រការ ១ :** ត្រូវបានតែងតាំងលោក ខន សារុន ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្តរតនគិរី ។

**ប្រការ ២ :** អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ អធិការ ប្រធានមន្ទីរទេសចរណ៍ខេត្តរតនគិរី និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**វ៉េង សេរីវុឌ្ឍ**

***

## ៧-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

### សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៩

**សេចក្តីសំរេចលេខ ២៣៨ សលរ.មស.ក្រខ**
**ស្តីពីការចេញចេកនិស្សិតចំនួន ០១ នាក់ ដែលទើបបញ្ចប់ការសិក្សាពីបរទេស**

***

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងលិខិតលេខ ៣១៩ សជណ.អវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**សំរេច**

**ប្រការ ១ :** អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកអោយទៅបំរើការងារ នៅក្រសួងដូចខាងក្រោមនេះ :

| លរ | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | អង្គភាព ដើម | មុខជំនាញ បច្ចេកទេស | កំរិតបណ្ណុះ បណ្តាល | កំរិត បៀវត្ស | អង្គភាពចូល បំរើការងារ | ប្រភពបណ្តុះ បណ្តាល |
|---|---|---|---|---|---|---|---|---|---|
| ១ | ភេង សុជាតិ | ប | ២៩-៥-៦៨ | សិស្ស | វេជ្ជសាស្ត្រ ទូទៅ | ឧត្តម | ៩០%ខ១ | ក្រសួងបរិស្ថាន | ប៉ូឡូញ |

**ប្រការ ២ :** ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនគាត់ជនចាប់ពីថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

**ប្រការ ៣ :** សេចក្តីសំរេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ពេជ្រ ម៉ុនធិន**

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ២៣៩ សសរ.មស.គ្រុខ

## ស្តីពីការបែងចែកនិស្សិតចំនួន ០២ នាក់ ដែលើប បញ្ចប់ការសិក្សាពីបរទេស

***

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងលិខិតលេខ ៣១៩ សជណ.អវ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកអោយទៅបំរើការងារ នៅក្រសួង- ស្ថាប័ន មួយចំនួន ដូចខាងក្រោមនេះ ៖

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃ ខែ ឆ្នាំ កំណើត | អង្គភាពដើម | មុខជំនាញបច្ចេកទេស | កំរិតបណ្ឌុះបណ្តាល | កំរិតរៀបចំ | អង្គភាពចូលបំរើការងារ | ប្រភពបណ្តុះបណ្តាល |
|---|---|---|---|---|---|---|---|---|---|
| ១ | កង ក្រិស្នា | ស | ២៨-៤-៧១ | សិស្ស | កសិកម្មតំបន់ក្តៅ | ប.វិទ្យា | ៩០%ខ១៤ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | គុយបា |
| ២ | ចាន់ សារិទ្ធ | ប | ៩ -៦ -៧២ | សិស្ស | រុក្ខកម្ម | ឧត្តម | ៩០%ខ១១ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អាល្លឺម៉ង់ |

ប្រការ ២ : ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនសាមីជនចាប់ពីថ្ងៃដែលបានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ពេជ្រ ប៊ុនធិន

★★★